អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ២១៥ .ស.ស. ១៤ អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អគ្គិសនីកម្ពុជា
ចូល
លេខ ៣៣៤៣ រ.ប.អ.ក
ថ្ងៃទី ២៤.១២.១៨ ម៉ោង ៣.៤០
បញ្ជូនទៅ

នាយកដ្ឋានអាជីវកម្មនិងអតិថិជន
ចូល
លេខ
ថ្ងៃទី ម៉ោង

# សេចក្តីសម្រេច

## ស្តីពីការកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា ពីប្រភពបណ្តាញជាតិ សម្រាប់ការលក់អគ្គិសនីដុំចេញពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ ២០១៩

## អាជ្ញាធរអគ្គិសនីកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- ប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ ០២៥៥.រថ.អវថ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីឡើងវិញ នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ការអនុវត្តបន្តពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២០
- យោងអាជ្ញាបណ្ណលេខ០០១.ឯអ ដែលបានចេញឲ្យអគ្គិសនីកម្ពុជា នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២
- យោងការគណនាថ្លៃអគ្គិសនីត្រូវលក់ចេញពីទ្វារចេញនៃអនុស្ថានីយ និងពីបណ្តាញបញ្ជូនរងដែលប្រភពចេញពីបណ្តាញជាតិរបស់អគ្គិសនីកម្ពុជា
- យោងការផ្សព្វផ្សាយពិគ្រោះយោបល់សាធារណៈ អំពីផែនការកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីប្រភពពីបណ្តាញជាតិ សម្រាប់ការលក់អគ្គិសនីដុំចេញពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ ២០១៩ ចាប់ពីថ្ងៃទី០៦ ខែវិច្ឆិកា រហូតដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨
- យោងការសម្រេចនៃសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី៣៣៧ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ។

## សម្រេច

### ប្រការ ១

កែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីរបស់ **អគ្គិសនីកម្ពុជា** សម្រាប់ការលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធុនដុំ និងធុនធំ ចេញពីទ្វារចេញនៃអនុស្ថានីយរបស់ប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនី និងពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ ឆ្នាំ២០១៩ តាមលក្ខខណ្ឌ និងអត្រា ដូចកំណត់ក្នុងតារាងខាងក្រោម ៖


**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៥៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

| ប្រភេទអ្នកប្រើប្រាស់ និងលក្ខខណ្ឌនៃការទិញ | អត្រាថ្លៃលក់ | សំគាល់ |
|---|---|---|
| ទិញអគ្គិសនីពីទ្វារចេន្តតង់ស្យុងខ្ពស់ HV នៃអនុស្ថានីយ | 0.1170 $US / kWh | អតិថិជនអាចធ្វើការទូទាត់ថ្លៃអគ្គិសនី ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការរបស់អគ្គិសនីកម្ពុជាដូចមានកំណត់ក្នុងប្រការ ៣ ។ |
| ទិញអគ្គិសនីពីទ្វារចេន្តតង់ស្យុងមធ្យម MV នៃអនុស្ថានីយនៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ | 0.1350 $US / kWh | |
| ទិញអគ្គិសនីពីទ្វារចេន្តតង់ស្យុងមធ្យម MV នៃអនុស្ថានីយនៅតាមខេត្ត | 0.1220 $US / kWh | |
| ទិញពីខ្សែចែកចាយ និងខ្សែបញ្ជូនរង តាមនាឡិកាស្ទង់ MV ប្រភេទឧស្សាហកម្ម | 0.1470 $US / kWh | |
| ទិញពីខ្សែចែកចាយ និងខ្សែបញ្ជូនរង តាមនាឡិកាស្ទង់ MV ប្រភេទពាណិជ្ជកម្ម និងរដ្ឋបាល | 0.1590 $US / kWh | |

## ប្រការ ២

កែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីរបស់ **អគ្គិសនីកម្ពុជា** សម្រាប់ការលក់អគ្គិសនីឲ្យ **អ្នកកាន់អាជ្ញាបណ្ណ** ចេញពីទ្វារចេន្តនៃអនុស្ថានីយរបស់ប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនី និងពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ តាមលក្ខខណ្ឌ និងអត្រា ដូចកំណត់ក្នុងតារាងខាងក្រោម ៖

| ប្រភេទអ្នកកាន់អាជ្ញាបណ្ណ និងលក្ខខណ្ឌនៃការទិញ | អត្រាថ្លៃលក់ | សំគាល់ |
|---|---|---|
| ទិញអគ្គិសនីពីទ្វារចេន្តតង់ស្យុងមធ្យម MV នៃអនុស្ថានីយ | 0.1180 $US / kWh | អតិថិជនអាចធ្វើការទូទាត់ថ្លៃអគ្គិសនី ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការរបស់អគ្គិសនីកម្ពុជា ដូចមានកំណត់ក្នុងប្រការ ៣ ។ |
| ទិញអគ្គិសនីពីខ្សែបញ្ជូនរង តាមនាឡិកាស្ទង់ MV | 0.1350 $US / kWh | |
| ទិញអគ្គិសនីពីខ្សែបញ្ជូនរង ក្រោមត្រង់ស្វូនិយោគដោយ «អ្នកទិញ» តាមនាឡិកាស្ទង់ LV | 0.1404 $US / kWh | |
| ទិញអគ្គិសនីពីខ្សែបញ្ជូនរង ក្រោមត្រង់ស្វូនិយោគដោយ «អ្នកលក់» តាមនាឡិកាស្ទង់ LV | 0.1484 $US / kWh | |

## ប្រការ ៣

ពិតមែនតែអត្រាថ្លៃអគ្គិសនីដែលកំណត់ក្នុងប្រការ ១ និង ប្រការ ២ ខាងលើ បានកំណត់ជាប្រាក់ដុល្លារសហរដ្ឋអាមេរិក ប៉ុន្តែ អ្នកប្រើប្រាស់អគ្គិសនីធុនធំ ធុនធំ និងអ្នកកាន់អាជ្ញាបណ្ណអាចធ្វើការទូទាត់ថ្លៃអគ្គិសនីជូនអគ្គិសនីកម្ពុជា ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការ ដែលអគ្គិសនីកម្ពុជាកំណត់លើមូលដ្ឋាននៃអត្រាប្តូរប្រាក់មធ្យមរបស់ធនាគារជាតិនៃកម្ពុជា និងអត្រាប្តូរប្រាក់ លី ហួរ ពីថ្ងៃទី២១ ដល់ថ្ងៃចុងខែ មុនថ្ងៃធ្វើវិក្កយបត្រ ។

## ប្រការ ៤

ក្នុងការទិញអគ្គិសនីតាមតង់ស្យុងខ្ពស់ និងតង់ស្យុងមធ្យម ពីអគ្គិសនីកម្ពុជាតាមការកំណត់ក្នុងប្រការ ១និងប្រការ ២ ខាងលើ អតិថិជនជាអ្នកកាន់អាជ្ញាបណ្ណ និងអ្នកប្រើប្រាស់ធុនធំ និងធុនធំ ត្រូវរក្សា

មេគុណអានុភាព (cosφ) នៃការទទួលអគ្គិសនីរបស់ខ្លួនឲ្យបិតនៅក្នុងកម្រិតគុណភាព cosφ≥ 0.9 ឬ tgφ ≤ 0.484 មានន័យថា អតិថិជនមានសិទ្ធប្រើប្រាស់ថាមពលរ៉េអាក់ទីវចេញពីប្រព័ន្ធផ្គត់ផ្គង់របស់អគ្គិសនីកម្ពុជាមិនលើសពីចំនួនកំណត់មួយដែលកំណត់ដោយ cosφ≥ 0.9 ឬ tgφ ≤ 0.484 ។ ក្នុងករណីដែលអតិថិជនខកខានពុំបានរក្សាមេគុណអានុភាពឲ្យបានដូចការកំណត់ខាងលើ ដោយប្រើប្រាស់ថាមពលរ៉េអាក់ទីវពីប្រព័ន្ធរបស់អគ្គិសនីកម្ពុជាលើសពីចំនួនកំណត់ អតិថិជននោះ ត្រូវបង់ថ្លៃបរិមាណថាមពលរ៉េអាក់ទីវដែលខ្លួនប្រើប្រាស់លើសនេះ តាមអត្រាថ្លៃថាមពលរ៉េអាក់ទីវស្មើនឹង 0.025$US ក្នុង១គីឡូវ៉ុលអំពែររ៉េអាក់ទីវម៉ោង (kVArh) ។

## ប្រការ ៥

ការលក់ និងទិញអគ្គិសនី តាមបញ្ជីថ្លៃលក់ដែលកំណត់ក្នុងប្រការ ១ និងប្រការ ២ ខាងលើ ត្រូវអនុវត្តតាមសេចក្តីពន្យល់ និងសេចក្តីណែនាំលម្អិតក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ ។

## ប្រការ ៦

អគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាបណ្ណ និងអ្នកប្រើប្រាស់អគ្គិសនីធុនធំ និងធុនធំ ដែលពាក់ព័ន្ធជាមួយបញ្ជីថ្លៃលក់កែសម្រួលថ្មីខាងលើ មានភារកិច្ចអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីនេះ ឲ្យមានប្រសិទ្ធភាព ។

## ប្រការ ៧

អត្រាថ្លៃថ្មីដែលបានកំណត់ខាងលើនេះ ត្រូវអនុវត្តចំពោះអ្នកកាន់អាជ្ញាបណ្ណដែលបានទិញបរិមាណអគ្គិសនីចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ដែលត្រូវនឹងការចេញវិក្កយបត្រចាប់ពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៩ និងសម្រាប់អ្នកប្រើប្រាស់ធុនធំ និងធុនធំ ដែលត្រូវធ្វើវិក្កយបត្រចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ តទៅ ។ ក្នុងករណីខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងអគ្គិសនីកម្ពុជា និងអ្នកទិញ បានចែងនូវអត្រាថ្លៃខុសពីការកំណត់ក្នុងប្រការខាងលើ អគ្គិសនីកម្ពុជា និងអ្នកទិញអគ្គិសនី ត្រូវធ្វើការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីនៅក្នុងកិច្ចព្រមព្រៀងទិញលក់នោះឡើងវិញជាបន្ទាន់ ដើម្បីអនុវត្តអត្រាថ្លៃលក់អគ្គិសនីឲ្យស្របតាមការកំណត់នៅក្នុងសេចក្តីសម្រេចនេះ ។ ការកែសម្រួលកិច្ចព្រមព្រៀងទិញលក់ឡើងវិញនេះ ប្រសិនបើមាន ត្រូវតែធ្វើយ៉ាងណាឲ្យអត្រាថ្លៃថ្មី អាចអនុវត្តចំពោះបរិមាណអគ្គិសនីដែលបានទិញចាប់ពីចុងខែធ្នូ ឆ្នាំ២០១៨ តទៅ ។

## ប្រការ ៨

ក្នុងករណីពិសេស អគ្គិសនីកម្ពុជាអាចស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា ធ្វើការសម្រេចដោយឡែកនូវអត្រាថ្លៃខុសពីអត្រាថ្លៃកំណត់ជាទូទៅនៅក្នុងប្រការ ២ ខាងលើ ដើម្បីប៉ះប៉ូវផ្តល់លទ្ធភាពឲ្យអ្នកកាន់អាជ្ញាបណ្ណបញ្ជូនវងណាមួយ អាចលក់អគ្គិសនីដុំឲ្យតំបន់ចែកចាយរបស់គេ តាមអត្រាថ្លៃដូចបានកំណត់ក្នុងប្រការ ២ ខាងលើ ។

## ប្រការ ៩

លើកលែងតែការកំណត់ពេលវេលាដែលចែងក្នុងប្រការ ៧ ខាងលើ ខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ដើម្បីអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ បញ្ជីថ្លៃលក់នេះ អាចធ្វើការកែសម្រួល

ឡើងវិញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ រាល់សេចក្តីសម្រេចស្តីពីថ្លៃលក់អគ្គិសនីចេញមុនទាំងឡាយ ដែលផ្ទុយពីខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១០**

អគ្គិសនីកម្ពុជាមានភារកិច្ចផ្សព្វផ្សាយអំពីខ្លឹមសារនៃសេចក្តីសម្រេចនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលមានការពាក់ព័ន្ធ ។

ថ្ងៃអង្គារ ៣រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**ឃីម ឌិសិដ្ឋ**

<u>ចម្លងជូន</u> ៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរ៉ែ និងថាមពល
-សាលារាជធានី-ខេត្ត ដែលពាក់ព័ន្ធ
-មន្ទីររ៉ែ និងថាមពល រាជធានី/ខេត្ត ដែលពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គិសនីកម្ពុជា
"ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ